# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **ខ្មែរ**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Aug-2019, 14:23
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## ចម្លើយតបរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ទៅនឹងសំណើកែប្រែរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងចម្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខ

---

**ដាក់ដោយ៖**

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

**ដាក់ជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele Mwachande MUMBA

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Cécile ROUBEIX
កញ្ញា Dounia HATTABI
លោក Stéphane NICOLAÏ

ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS (ព្រះរាជអាជ្ញាបម្រុង)
លោក William SMITH (ព្រះរាជអាជ្ញារង)

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ មេធាវីការពារក្ដីលោក ខៀវ សំផន ("មេធាវីការពារក្ដី") បានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") ឱ្យបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ សម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ និងបន្ថែមពេលវេលា ដើម្បីឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[1]។

២. នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការស្នើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ សម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ដោយស្នើសុំថា ការបន្ថែមណាមួយជូនមេធាវីការពារក្ដីត្រូវធ្វើឡើង "ក្នុងលក្ខណៈសមាមាត្រគ្នា" ទៅនឹងសារណាតបរបស់ខ្លួន[2]។

៣. នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ខណៈខ្លួនជំទាស់នឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់មេធាវីការពារក្ដីលោក នួន ជា[3] សហព្រះរាជអាជ្ញាបែរជាស្នើសុំ "៧០% នៃចំនួនទំព័រសរុបរួម និង ៥០% នៃពេលវេលារួម ដែលផ្ដល់ជូនមេធាវីការពារក្ដី" សម្រាប់សារណាតបរបស់ខ្លួន[4]។

៤. នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ មេធាវីការពារក្ដីបានស្នើសុំឱ្យតុលាការកំពូលបដិសេធសំណើថ្មីនេះរបស់សហព្រះរាជអាជ្ញា ដោយហេតុថា សំណើយឺតពេលនេះគ្មានមូលដ្ឋានគាំទ្រ និងមិនសមហេតុផល ហើយបានស្នើសុំឱ្យតុលាការកំពូលសម្រេចជាបន្ទាន់លើសំណើទាំងអស់[5]។

---

[1] សំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាបណ្ដឹងសាទុក្ខ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ F45។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សារណាបណ្ដឹងសាទុក្ខ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ F45/2 (ជូនដំណឹងនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩) កថាខណ្ឌ ១៧ កថាខណ្ឌ ១៨ និងកថាខណ្ឌ ២២។

[3] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំពេលវេលា និងចំនួនទំព័របន្ថែម សម្រាប់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ ឯកសារ F47/1។

[4] ចម្លើយតប/សំណើ F47/1 កថាខណ្ឌ ២៥-២៦(ii)។

[5] ចម្លើយតបរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងចម្លើយតបទៅនឹង

៥. នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ តុលាការកំពូលបានប្រកាសអំពីការបញ្ចប់កិច្ចដំណើរការនីតិវិធីលើលោក នួន ជា ដែលបានទទួលមរណភាពកាលពី ៩ ថ្ងៃមុន[6]។

៦. នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ មេធាវីការពារក្ដីបានផ្ញើអ៊ីមែលជូនតុលាការកំពូលសុំផ្ដល់ព័ត៌មានដល់ភាគីជាបន្ទាន់អំពីការចេញសេចក្ដីសម្រេចលើសំណើ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ឲ្យបានមុនពេលជូនដំណឹងអំពីសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដែលនឹងត្រូវដាក់នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩[7]។

៧. នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ភាគីបានទទួលការជូនដំណឹងអំពើសំណើ "កែប្រែ" របស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងចម្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី[8]។

៨. តាមរយៈសារណានេះ មេធាវីការពារក្ដីសូមឆ្លើយតបទៅនឹងសំណើលើកទីបីនេះរបស់សហព្រះរាជអាជ្ញា។ មេធាវីការពារក្ដីដាក់ចម្លើយតបយ៉ាងឆាប់រហ័សបែបនេះ ដើម្បីកុំឲ្យសំណើថ្មីនេះធ្វើឲ្យយឺតយ៉ាវថែមទៀត ដល់ការចេញសេចក្ដីសម្រេចរបស់តុលាការកំពូល លើរយៈពេលនៃបណ្ដឹងសាទុក្ខ។

៩. សហព្រះរាជអាជ្ញាមានចេតនា "កែប្រែ" សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ ក្រោយមរណភាពរបស់លោក នួន ជា ដែលខ្លួនលែងចាំបាច់ត្រូវឆ្លើយតប[9]។ ក៏ប៉ុន្តែ តាមពិត សហព្រះរាជអាជ្ញា

---

សារណាបណ្ដឹងសាទុក្ខ [ឯកសារ F47/1 កថាខណ្ឌ ២៥-២៦(ii)] ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F47/3** ("ចម្លើយតប **F47/3**")។

[6] សេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F46/3**។

[7] អ៊ីមែលរបស់មេធាវីការពារក្ដីផ្ញើជូនក្រឡាបញ្ជី នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១២ និង ៣៨ នាទី មានចំណងជើងថា "សំណើបន្ទាន់បំផុតសុំឲ្យចេញសេចក្ដីសម្រេចលើសំណើ F45" (ភ្ជាប់ជូនជាឧបសម្ព័ន្ធ)។

[8] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំកែប្រែទៅលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់សារណាតបទៅនឹងបណ្ដឹងសាទុក្ខ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F48** ជូនដំណឹងនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ("សំណើកែប្រែ **F48**")។ មេធាវីការពារក្ដីបានធ្វើការ ដោយផ្អែកលើសំណៅបកប្រែព្រាងដំបូងមិនពេញលេញជាភាសាបារាំង ដែលផ្ដល់ជូនដោយអង្គភាពបកប្រែភាសា ដោយសារតែមិនអាចបកប្រែឯកសារទាន់ពេលវេលា។

ស្នើសុំជាថ្មីម្តងទៀត ដើម្បីទទួលបានពេលវេលា និងចំនួនទំព័របន្ថែមដូចគ្នានឹងការផ្តល់ជូនមេធាវីការពារក្តី[10]។ ការកែប្រែពិតប្រាកដតែមួយគត់ គឺការស្នើសុំដាក់សារណាតប ក្នុងរយៈពេលយ៉ាងហោចណាស់ ២៥ ថ្ងៃ (ជំនួសឱ្យ ៤៥ ថ្ងៃ) ក្រោយពេលសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីត្រូវបានជូនដំណឹង ជាភាសាខ្មែរ[11]។

១០. តាមពិត ចាប់តាំងពីមរណភាពរបស់លោក នួន ជា និងការបញ្ចប់កិច្ចដំណើរការនីតិវិធីលើរូបគាត់មក សហព្រះរាជអាជ្ញាបានឆ្លៀតឱកាសបង្ហាញមូលដ្ឋានគាំទ្រដល់សំណើរបស់ខ្លួន។

១១. ពាក់ព័ន្ធនឹងចំនួនទំព័រ សហព្រះរាជអាជ្ញាផ្អែកលើសេចក្តីណែនាំអនុវត្តន៍របស់ អ.វ.ត.ក និងវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត[12]។ សំណើរបស់សហព្រះរាជអាជ្ញាស្របទៅតាមយុត្តិសាស្ត្ររបស់តុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១ ដែលមេធាវីការពារក្តីបានស្នើសុំឱ្យអនុវត្ត[13]។

១២. ប៉ុន្តែ ចំពោះពេលវេលាកំណត់ ទឡ្ហីករណ៍ថ្មីៗរបស់សហព្រះរាជអាជ្ញានៅតែមិនបានធ្វើឱ្យសំណើរបស់ខ្លួនមានភាពសមហេតុផល និងមិនអាចយកជាការបានឡើយ។ សហព្រះរាជអាជ្ញាលើកឡើងអំពីសេចក្តីសម្រេចដែលបានចេញក្នុងរឿងក្តីពីររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលខ្លួនចៀសវាងក្នុងការបញ្ជាក់ថា មូលហេតុនៃការចេញសេចក្តីសម្រេចទាំងនេះ គឺដោយសារគិតគូរដល់ការអនុវត្ត ដោយផ្អែកលើពេលវេលាសមកាល សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខ និងសារណាតប មិនមែនព្រោះតែភាគីចុងចម្លើយគួរទទួលបានពេលវេលាដូចគ្នានឹងម្ចាស់បណ្តឹងសាទុក្ខនោះទេ[14]។ ក្នុងរឿងក្តីនេះ ការផ្តល់ពេលវេលាច្រើនដល់សហព្រះរាជអាជ្ញា (ខណៈដែល

---

[9] សំណើកែប្រែ F48 កថាខណ្ឌ ១ និងកថាខណ្ឌ ៧។

[10] សំណើកែប្រែ F48 កថាខណ្ឌ ២ កថាខណ្ឌ ១១ និងកថាខណ្ឌ ១២, ចម្លើយតប F47/3 កថាខណ្ឌ ៨ ដល់កថាខណ្ឌ ១២។

[11] សំណើកែប្រែ F48 កថាខណ្ឌ ១១ ដល់កថាខណ្ឌ ១២ និងកំណត់សម្គាល់ជើងទំព័រលេខ ២៨។

[12] សំណើកែប្រែ F48 កថាខណ្ឌ ៨។

[13] ចម្លើយតប F47/3 កថាខណ្ឌ ៩ និងកំណត់សម្គាល់ជើងទំព័រលេខ ១៣ កថាខណ្ឌ ២៤។

[14] សំណើកែប្រែ F48 កថាខណ្ឌ ៩ និងកំណត់សម្គាល់ជើងទំព័រលេខ ២៥ (សេចក្តីសម្រេចទាំងពីរ ដែលបានចេញនៅក្នុងរឿងក្តី

មេធាវីការពារក្ដីឆ្លើយតបរួចហើយទៅនឹងសារណាបណ្ដឹងសាទុក្ខ) នឹងរឹតតែធ្វើឱ្យកិច្ចដំណើរការនីតិវិធីអូសបន្លាយពេល ដោយមិនត្រឹមត្រូវ។

១៣. បន្ទាប់មកទៀត សហព្រះរាជអាជ្ញាធ្វើ "យុត្តិកម្ម" លើសំណើសុំពេលវេលាបន្ថែមរបស់ខ្លួន ដោយផ្អែកលើសម្មតិកម្មថា ខ្លួនមាន "កាតព្វកិច្ចក្នុងការព្យាយាមបកស្រាយ និងឆ្លើយតប" នឹងមូលដ្ឋាន "មិនពេញលេញ" និង "មិនច្បាស់លាស់" ដែលនឹងលើកឡើងនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី[15]។ ប៉ុន្តែ សហព្រះរាជអាជ្ញាដឹងច្បាស់អំពីគោលជំហររបស់តុលាការកំពូល (និងតុលាការព្រហ្មទណ្ឌអន្តរជាតិ) លើប្រធានបទនេះ៖ សេចក្ដីសន្និដ្ឋាន "មានលក្ខណៈមិនច្បាស់លាស់ មានលក្ខណៈផ្ទុយ និងមានលក្ខណៈស្រពេចស្រពិល" នឹងមិនត្រូវលើកយកមកពិចារណាឡើយ[16]។ ដូច្នេះ សហព្រះរាជអាជ្ញាដឹងច្បាស់ថា ខ្លួនអាចមិនចាំបាច់ត្រូវឆ្លើយតប និងមិនត្រូវការពេលវេលាបន្ថែមនោះទេ ក្នុងសម្មតិកម្មបែបនេះ។

១៤. ហេតុដូចនេះ មេធាវីការពារក្ដីរក្សាទឡ្ហីករណ៍ទាំងអស់នៅដដែល ដែលបានលើកឡើងយ៉ាងលម្អិតនៅក្នុងចម្លើយតបទៅនឹងសំណើពីមុនរបស់សហព្រះរាជអាជ្ញា គឺសហព្រះរាជអាជ្ញាគួរដាក់ចម្លើយតប ជាពីរភាសា មិនឱ្យលើសពី ១៥ ថ្ងៃ ក្រោយពេលជូនដំណឹងអំពីសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ជាភាសាខ្មែរ។ មេធាវីការពារក្ដីសូមយោងទៅទឡ្ហីករណ៍ទាំងនោះ ដើម្បីកុំឱ្យមានភាពច្រំដែល[17]។

---

*Karadžić* បានផ្ដល់សំអាងហេតុដូចតទៅ៖ "ដើម្បីប្រយោជន៍យុត្តិធម៌ និងគ្រប់គ្រងរឿងក្ដីឱ្យមានប្រសិទ្ធភាព ត្រូវអនុវត្តដោយផ្អែកលើពេលវេលាសមកាល សម្រាប់ការដាក់សារណា"។ ការពិចារណានេះត្រូវបានដកស្រង់នៅក្នុងសេចក្ដីសម្រេច ក្នុងរឿងក្ដី *Mladić* ដែលបានយោងដល់សេចក្ដីសម្រេចទាំងពីរនេះ)។

[15] សំណើកែប្រែ **F48** កថាខណ្ឌ ១០។

[16] សាលដីកាលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** កថាខណ្ឌ ១០១ ដល់កថាខណ្ឌ ១០២, សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ និងពេលវេលា ក្នុងការឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **F23/1** កថាខណ្ឌ ៩ (តុលាការកំពូលបដិសេធយ៉ាងដាក់កណ្ដាក់នូវទឡ្ហីករណ៍ប្រភេទនេះ ដែលសហព្រះរាជអាជ្ញាបានលើកឡើងរួចមកហើយ)។

[17] ចម្លើយតប **F47/3** កថាខណ្ឌ ៨ ដល់កថាខណ្ឌ ២២។

១៥. ដូចគ្នាផងដែរ មេធាវីការពារក្ដីនៅតែស្នើសុំឲ្យតុលាការកំពូលផ្ដល់ព័ត៌មានឲ្យបានឆាប់បំផុតអំពីការចេញសេចក្ដីសម្រេចលើសំណើ ចុះថ្ងៃទី១០ ខែកក្កដា កន្លងទៅនេះ ពីព្រោះខ្លួនត្រូវការដាច់ខាតដើម្បីអាចរៀបចំធនធានតិចតួចស្ដួចស្ដើងដែលខ្លួនមានឲ្យបានល្អ ជាពិសេស ដោយសារកៀកពេលជូនដំណឹងអំពីសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[18]។

១៦. <u>**អាស្រ័យហេតុនេះ**</u> មេធាវីការពារក្ដីស្នើសុំតុលាការកំពូលមេត្តា៖

- **ផ្ដល់**ឲ្យសហព្រះរាជអាជ្ញានូវការបន្ថែមសមាមាត្រសម្រាប់សារណាតប ស្របតាមយុត្តិសាស្ត្ររបស់តុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១
- **សម្រេចជាបន្ទាន់**លើសំណើរបស់មេធាវីការពារក្ដី ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ បើទោះជាត្រូវចេញផ្នែកសម្រេចសេចក្ដីជាមុន (តាមអ៊ីមែលក៏បាន) រួចទើបចេញសំអាងហេតុជាក្រោយក៏ដោយ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |

[18] ចម្លើយតប F47/3 កថាខណ្ឌ ២៣ ដល់កថាខណ្ឌ ២៤, អ៊ីមែល ផ្ញើនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ (សូមមើលខាងលើ កំណត់សម្គាល់ជើងទំព័រលេខ ៧)។